ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.....០០៣.....សហវ

សេចក្តីណែនាំ
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា ឱ្យបានជ្រាបថា អនុវត្តស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំនូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មី ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ធានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជម្រាបជូនថា គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា ត្រូវដាក់លិខិតប្រកាសសម្រាប់រយៈពេលជាប់ពន្ធខែមិថុនា ឆ្នាំ២០២០ តរៀងទៅ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដូចខាងក្រោម÷

I. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ

អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ត្រូវដាក់លិខិតប្រកាសដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម ១0% ពីការយឺតយ៉ាវក្នុងការដាក់លិខិតប្រកាស។ ដោយឡែក ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធមធ្យមអាចបំពេញលិខិតប្រកាសដោយដៃនិងដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ ប៉ុន្តែត្រូវបន្តការប្រើប្រាស់ការស្នើសុំបង្វិលសងឬឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (Online-VAT Refund and Online-VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២0 នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង។ អគ្គនាយកដ្ឋានពន្ធដារនឹងចេញសេចក្តីណែនាំបន្ថែមស្តីពីអំពីការកំណត់រយៈពេលសមស្របក្នុងការបញ្ចប់ការពន្យារការអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing)។ ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) អ្នកជាប់ពន្ធមធ្យមនិងធំត្រូវអនុវត្តដូចខាងក្រោម÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

១. ការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដើម្បីចុះបញ្ជីប្រើប្រាស់ប្រព័ន្ធ ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (VAT TIN)
- លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានផ្តល់ជូនលោក-លោកស្រី
- លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គ-នាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះសម្រាប់ប្រើប្រាស់ (User Name) និង លេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) អ្នកប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម÷

- ចូលទៅគេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ដោយប្រើប្រាស់គណនីប្រើប្រាស់ប្រព័ន្ធ និងជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ
- បញ្ចូលទិន្នន័យបញ្ជីនិងវិក្កយបត្រទិញ-លក់
- បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការប្រកាសពន្ធកាត់ទុក
- បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការប្រកាសពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ក្នុងករណីនេះអ្នកជាប់ពន្ធពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។ ដោយឡែក ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធមកកាន់រដ្ឋបាលសារពើពន្ធដែលគ្រប់គ្រងសហគ្រាសនោះ។

II. សម្រាប់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចអាចដាក់លិខិតប្រកាសដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង ដោយរួចផុតពីពន្ធបន្ថែម ១០% ពីការយឺតយ៉ាវក្នុងការដាក់លិខិតប្រកាស។ ចំពោះ ការបំពេញលិខិតប្រកាសដោយដៃ អ្នកជាប់ពន្ធតូចត្រូវដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការទាក់ទិននឹងពន្ធអាករទាំងនោះបានកើតឡើង។ ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) អ្នកជាប់ពន្ធតូចត្រូវអនុវត្តដូចខាងក្រោម÷

១. ការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ អ្នកប្រើប្រាស់ដែលពុំទាន់បានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធដោយចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន www.tax.gov.kh ឬទាញយកពី App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬទាញយកពី Play Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) ដោយត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- លេខអត្តសញ្ញាណកម្មសារពើពន្ធ (BIN)
- លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានផ្តល់ជូនលោក-លោកស្រី
- លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គ-នាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

អ្នកប្រើប្រាស់នឹងទទួលបាន ឈ្មោះសម្រាប់ប្រើប្រាស់ (User Name) និង លេខកូដសម្ងាត់ (Password) ដែលត្រូវបានផ្ញើទៅកាន់អ៊ីម៉ែល (E-mail) និងលេខទូរស័ព្ទរបស់ម្ចាស់សហគ្រាសឬអ្នកប្រើប្រាស់ នៅពេលព័ត៌មានដែលតម្រូវខាងលើត្រូវបានវាយបញ្ចូលពេញលេញ។

២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Taxpayer App) អ្នកប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម÷

- បញ្ចូលទិន្នន័យទិញ-លក់របស់សហគ្រាស
- ពិនិត្យប្រាក់ពន្ធដែលគណនាដោយស្វ័យប្រវត្តិ
- ត្រូវបំពេញបន្ថែមប្រាក់ពន្ធ-អាករផ្សេងៗប្រសិនបើមាន
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ក្នុងករណីនេះអ្នកជាប់ពន្ធពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។ ដោយឡែក ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធមកកាន់រដ្ឋបាលសារពើពន្ធដែលគ្រប់គ្រងសហគ្រាសនោះ។

III. ទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ

ចំពោះករណីបំពេញនិងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែ អ្នកជាប់ពន្ធត្រូវអនុវត្តដូចខាងក្រោម÷

- បំពេញនិងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែស្របតាមទម្រង់លិខិតប្រកាសប្រចាំខែថ្មី ដូចមានភ្ជាប់ជាមួយសេចក្តីណែនាំនេះ ឬអាចទាញយកពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh
- ប្រកាសនិងបង់ប្រាក់ពន្ធគ្រប់ប្រភេទសម្រាប់ខែនីមួយៗយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់

- លិខិតប្រកាសបង់ពន្ធប្រចាំខែថ្មីត្រូវរៀបចំសម្រាប់គ្រប់ប្រភេទពន្ធដែលត្រូវប្រកាសប្រចាំខែ ហើយចំពោះសហគ្រាសដែលមានសាខា លិខិតប្រកាសពន្ធប្រចាំខែត្រូវមានលិខិតប្រកាសពន្ធសម្រាប់ទីស្នាក់ការកណ្តាល សាខារបស់សហគ្រាស និងលិខិតប្រកាសពន្ធសរុបប្រចាំខែ
- អ្នកជាប់ពន្ធត្រូវបន្តការប្រើប្រាស់ការស្នើសុំបង្វិលសងឬឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (Online-VAT Refund and Online-VAT Credit) ស្របតាមសេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ដើម្បីធ្វើការស្វែងយល់បន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មី អ្នកប្រើប្រាស់អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ www.tax.gov.kh ឬចូលទស្សនាវីដេអូណែនាំ (Video Tutorial) ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិការសហគ្រាសទាំងអស់ ក៏ដូចជា បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ ដើម្បីធ្វើការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែឱ្យបានត្រឹមត្រូវនិងទទួលបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ[illegible]ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ ហ ង ជ័ន្ធមុនីរ៉ា

ចម្លងជូន÷
- ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីមុខការ"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីចូលរួមផ្សព្វផ្សាយ"
- ស្ថានបេសកកម្មរបស់ប្រទេសនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា
- ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា
- អង្គការអន្តរជាតិនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លិខិតប្រកាសពន្ធ-សរុប
TOTAL TAX RETURN (TTR001)

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតប្រកាសពន្ធសរុបប្រចាំខែ
TOTAL MONTHLY TAX RETURN

ប្រចាំខែ Month [M M] ឆ្នាំ Year [Y Y Y Y]

I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) [ ] - [ ]

ឈ្មោះសហគ្រាស/ស្ថាប័នដទៃទៀត
Name of enterprise/Other entities

សកម្មភាពអាជីវកម្មចម្បង
Main business activity

អាសយដ្ឋាន
Address

តើក្រុមហ៊ុនរបស់លោកអ្នកមានសាខា ឬឃ្លាំងដែរទេ? Does your enterprise have any branches or warehouses? ☐ គ្មាន No ☐ មាន Yes ▶ ចំនួនសាខាឬឃ្លាំងសរុប Total branches or warehouses [ ] សូមបំពេញលិខិតប្រកាសពន្ធ-សាខា Please fill Monthly Tax Return-Branch

II. ប្រភេទពន្ធដែលត្រូវប្រកាស / TYPE OF TAXES TO BE DECLARED

ល.រ No.	បរិយាយ Description	ស្រង់មកពីទម្រង់លិខិតប្រកាសពន្ធ From tax return form	ចំនួនទំព័រ Number of pages	កំណាន់ដានយោង ឬបង្វិលសង Credit carried forward or refund	ចំនួនប្រាក់ពន្ធត្រូវបង់ Tax amount to be paid
០១	ពន្ធលើប្រាក់បៀវត្ស Tax on Salary	ទម្រង់ ពបវ ០១ Form TOS 01 (ទីស្នាក់ការ និងគ្រប់សាខា) Headquarter and All branches			រៀល
០២	ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benefit				រៀល
០៣	ពន្ធកាត់ទុក Withholding Tax	ទម្រង់ ពកទ ០៣ Form WT 03 (ទីស្នាក់ការ និងគ្រប់សាខា) Headquarter and All branches			រៀល
០៤	អាករលើតម្លៃបន្ថែម Value Added Tax (VAT)	ទម្រង់ ព៧ ០១ Form T7 01 (ទីស្នាក់ការ និងគ្រប់សាខា) Headquarter and All branches		☐ កំណាន់ដានយោងទៅមុខ Credit carried forward [ ] រៀល ☐ បង្វិលសង Refund [ ] រៀល	រៀល
០៥	ប្រាក់រំដោះពន្ធលើប្រាក់ចំណូល Prepayment of Tax on Income			☐ កំណាន់ដានយោងទៅមុខ Credit carried forward [ ] រៀល	រៀល
០៦	អាករពិសេសលើទំនិញ និងសេវាមួយចំនួន Specific tax on Certain Merchandises and Services				រៀល
០៧	អាករលើការស្នាក់នៅ Accomodation Tax				រៀល
០៨	អាករសម្រាប់បំភ្លឺសាធារណៈ Public for Lighting Tax				រៀល
០៩	ពន្ធ-អាករដទៃទៀត Other Taxes				រៀល
	**សរុប Total				រៀល

* *សូមអានសេចក្តីណែនាំ នៃការបំពេញលិខិតប្រកាស Please read the Instructions for filling tax return

សម្រាប់មន្ត្រីពន្ធដារ / FOR TAX OFFICIAL

លេខចូល In Number

កាលបរិច្ឆេទទទួល Date [D D] [ ] [ ] [Y Y Y Y]

ហត្ថលេខា Signature

ឈ្មោះ Name

តួនាទី Position

លេខសម្គាល់មន្ត្រី ID number

ធ្វើនៅ Filed In, [ ] [D D] [M M] [Y Y Y Y]

អភិបាល / បណ្ណាធិការ / កម្មសិទ្ធិករ សហគ្រាស / ភ្នាក់ងារសេវាកម្មពន្ធដារ
Director / Manager / Owner of Enterprise / Tax agent
ហត្ថលេខា ឈ្មោះ និងត្រា
Signature, Name and Seal

ប្រសិនជា ភ្នាក់ងារសេវាកម្មពន្ធដារ សូមបំពេញលេខសម្គាល់អាជ្ញាប័ណ្ណ
If you are a Tax agent, Please fill in your license number

សេចក្តីណែនាំអំពីការបំពេញ
ទម្រង់លិខិតប្រកាសពន្ធសរុបប្រចាំខែ
(ទម្រង់ TTR001)

- ត្រូវបំពេញខែ និងឆ្នាំដែលត្រូវដាក់លិខិតប្រកាស

I. ព័ត៌មានសហគ្រាស

- បំពេញលេខអត្តសញ្ញាណកម្មសារពើពន្ធ ឈ្មោះសហគ្រាស/ស្ថាប័នផ្ទៃទៀត សកម្មភាពអាជីវកម្មចម្បង និងអាសយដ្ឋាន
- ចំពោះសហគ្រាសដែលមានសាខាឬឃ្លាំង ត្រូវជ្រើសរើសយក "មាន" រួចបំពេញចំនួនសាខាឬឃ្លាំងសរុប និងបំពេញលិខិតប្រកាសពន្ធសម្រាប់សាខា
- ចំពោះសហគ្រាសដែលគ្មានសាខាឬឃ្លាំង ត្រូវជ្រើសរើសយក "គ្មាន" ដោយមិនចាំបាច់បំពេញលិខិតប្រកាសពន្ធសម្រាប់សាខាឡើយ។

II. ប្រភេទពន្ធដែលត្រូវប្រកាស

- បំពេញចំនួនប្រាក់ពន្ធត្រូវបង់តាមប្រភេទពន្ធនីមួយៗ ដោយដកស្រង់ចេញពីទម្រង់លិខិតប្រកាសពន្ធដែលបានបញ្ជាក់នៅក្នុងតារាងនៅក្រោយបរិយាយប្រភេទពន្ធនីមួយៗ ដោយធ្វើការបូកសរុបចំនួនប្រាក់ពន្ធត្រូវបង់ របស់ទីស្នាក់ការកណ្តាល និងគ្រប់សាខា រួចបំពេញនៅក្នុងប្រអប់ "ចំនួនប្រាក់ពន្ធត្រូវបង់"
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *ពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម* ត្រូវបូកសរុបចេញពីទម្រង់ *<u>ពបវ ០១</u>* របស់ទីស្នាក់ការកណ្តាល និងគ្រប់សាខា
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *ពន្ធកាត់ទុក* ត្រូវបូកសរុបចេញពីទម្រង់ *<u>ពកទ ០៣</u>* របស់ទីស្នាក់ការកណ្តាល និងគ្រប់សាខា
- ចំនួនប្រាក់ពន្ធដែលត្រូវបង់សម្រាប់ *អាករលើតម្លៃបន្ថែម ឬស្នើសុំជាឥណទានយោងទៅមុខ ឬបង្វិលសង* ត្រូវដកស្រង់ពីការគណនានៅចំណុចខ នៃទំព័រទី២ នៃលិខិតប្រកាសពន្ធសរុបប្រចាំខែនេះ។ ក្នុងករណី សហគ្រាសមានឥណទានអាករលើតម្លៃបន្ថែម ត្រូវជ្រើសរើសយក "ឥណទានយោងទៅមុខ" រួចបំពេញចំនួនទឹកប្រាក់តាមប្រអប់លេខ ០៩ នៃទំព័រទី២ "ជាឥណទានយោងទៅមុខ" នៅត្រង់ប្រអប់ "ឥណទានយោងទៅមុខ" នៅទំព័រទី១។ ក្នុងករណី សហគ្រាសមានឥណទានអាករលើតម្លៃបន្ថែម ហើយមានបំណងស្នើសុំបង្វិលសង ត្រូវជ្រើសរើសយក "បង្វិលសង" រួចបំពេញចំនួនទឹកប្រាក់តាមប្រអប់លេខ ១០ នៃទំព័រទី២ "បង្វិលសង" នៅត្រង់ប្រអប់ "បង្វិលសង" នៅទំព័រទី១។ ក្នុងករណី សហគ្រាសមានប្រាក់ពន្ធត្រូវបង់ ដែលជាលទ្ធផលនៃការគណនានៅទំព័រទី២ នៃលិខិតប្រកាសពន្ធសរុបប្រចាំខែនេះ ត្រូវបំពេញចំនួនប្រាក់ពន្ធដែលត្រូវបង់ នៅត្រង់ប្រអប់ "ចំនួនប្រាក់ពន្ធត្រូវបង់" សម្រាប់អាករលើតម្លៃបន្ថែម ស្របតាមប្រអប់លេខ ៨ "អតប ត្រូវបង់" នៅទំព័រទី២
- ចំនួនប្រាក់ពន្ធដែលត្រូវបង់សម្រាប់ *ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ឬស្នើសុំជាឥណទានយោងទៅមុខ* ត្រូវដកស្រង់ពីការគណនានៅចំណុចក នៃទំព័រទី២ នៃលិខិតប្រកាសពន្ធសរុបប្រចាំខែនេះ។ ក្នុងករណី សហគ្រាសមានឥណទានយោងទៅមុខ ហើយមានបំណងប្រើប្រាស់ជាឥណទានយោងទៅមុខ ត្រូវជ្រើសរើសយក "ឥណទានយោងទៅមុខ" រួចបំពេញចំនួនទឹកប្រាក់តាមប្រអប់លេខ ០៤ នៃទំព័រទី២ "ឥណទានយោងទៅមុខ" នៅត្រង់ប្រអប់ "ឥណទាន

III. ប្រតិបត្តិការសរុប / TOTAL TRANSACTIONS

ក. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល / PREPAYMENT OF TAX ON INCOME

ប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងខែ (ទីស្នាក់ការកណ្តាល+គ្រប់សាខា) Prepayment of tax on income (headquarter + all branches)		01	៛
ឥណទានយោងពីខែមុន Credit carried last month		02	៛
ប្រសិនបើប្រអប់លេខ 01 ដកប្រអប់លេខ 02 > ជាងសូន្យ៖ If box 01 - 02 > 0 for:	▶ ប្រាក់រំដោះពន្ធត្រូវបង់ PPI to be paid	03	៛
ប្រសិនបើប្រអប់លេខ 01 ដកប្រអប់លេខ 02 < ជាងសូន្យ៖ If box 01 - 02 < 0 for:	▶ ឥណទានយោងទៅមុខ As a credit forward	04	៛

ខ. អាករលើតម្លៃបន្ថែម / VALUE ADDED TAX

ឥណទានយោងពីខែមុន Tax credit carried from last month	លេខបារកូដឥណទានយោង Credit carried barcode	05	៛
សរុបទឹកប្រាក់ អាករលើធាតុចូល (ទីស្នាក់ការកណ្តាល+គ្រប់សាខា) Total amount of input tax (headquarter + all branches)		06	៛
សរុបទឹកប្រាក់ អាករលើធាតុចេញ (ទីស្នាក់ការកណ្តាល+គ្រប់សាខា) Total amount of out put tax (headquarter + all branches)		07	៛
ប្រសិនបើប្រអប់លេខ 07 ដកប្រអប់លេខ (05 + 06) > ជាងសូន្យ៖ If box 07 - (05+06) > 0 for:	▶ អតប ត្រូវបង់ VAT to be paid	08	៛
ប្រសិនបើប្រអប់លេខ 07 ដកប្រអប់លេខ (05 + 06) < ជាងសូន្យ៖ If box 07 - (05+06) < 0 for:	▶ ជាឥណទានយោងទៅមុខ As a credit forward	09	៛
	បង្វិលសង Refund	10	៛

សម្គាល់៖
Note :

- ការទទួលលិខិតប្រកាសមិនបញ្ជាក់ថា ការប្រកាសពន្ធត្រឹមត្រូវឡើយ
  Receiving Tax Return doesn't mean your Tax Return declaration is correct
- ករណីលោកលោកស្រីត្រូវការធ្វើបច្ចុប្បន្នភាពព័ត៌មាន សូមអញ្ជើញមកទំនាក់ទំនងនៅការិយាល័យចុះបញ្ជី ជាន់ទី០៦ នៃសាលាជាតិពន្ធដារ
  In case, You need to update information Please contact Tax Registration Bureau at 6th floor of Tax school
- លោក / លោកស្រី ត្រូវដាក់លិខិតប្រកាសនេះព្រមទាំងបង់ប្រាក់ពន្ធអាករយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់
  You must fill tax returned pay tax due by the 20th day of the next month.
- លោក / លោកស្រី នឹងទទួលរងការផាកពិន័យ ទៅតាមច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើលោក / លោកស្រី
  You will be subject to penalties according to law on taxation if you.
  - មិនបានដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ ទោះបីជាគ្មានប្រាក់អាករត្រូវបង់ក៏ដោយ
    Fail to file tax return to the tax administration even it is a nil return.
  - មិនបង់ ឬបង់យឺតយ៉ាវ នូវប្រាក់អាករដែលបានប្រកាស
    Do not pay or pay the tax declared late.
  - ធ្វើការប្រកាសក្លែងក្លាយ ឬបន្ទំ
    Making a false declaration.

យោងទៅមុខ” នៅទំព័រទី១។ ក្នុងករណី សហគ្រាសមានប្រាក់រំដោះពន្ធលើប្រាក់ចំណូលត្រូវបង់ ដែលជាលទ្ធផលនៃការគណនានៅទំព័រទី២ នៃលិខិតប្រកាសពន្ធសរុបប្រចាំខែនេះ ត្រូវបំពេញចំនួនប្រាក់ពន្ធដែលត្រូវបង់នៅត្រង់ប្រអប់ “ចំនួនប្រាក់ពន្ធត្រូវបង់” សម្រាប់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ស្របតាមប្រអប់លេខ ០៣ “ប្រាក់រំដោះពន្ធត្រូវបង់” នៅទំព័រទី២

- ចំនួនប្រាក់ពន្ធដែលត្រូវបង់សម្រាប់ *អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករលើការស្នាក់នៅ អាករសម្រាប់បំភ្លឺសាធារណៈ និងពន្ធ-អាករដទៃទៀត* ត្រូវដកស្រង់ដោយបូកសរុបចំនួនប្រាក់ពន្ធតាមប្រភេទពន្ធនីមួយៗចេញពីទម្រង់ *ព.ភ ០១* របស់ទីស្នាក់ការកណ្តាល និងគ្រប់សាខា
- ចំនួនទំព័រ ត្រូវបូកសរុបចំនួនទំព័រនៃលិខិតប្រកាសពន្ធតាមទម្រង់នីមួយៗរបស់ទីស្នាក់ការកណ្តាល និងគ្រប់សាខាបន្ទាប់ពីបានបំពេញរួចរាល់ និងត្រូវបំពេញចំនួនសរុបនៃទំព័រ និងចំនួនប្រាក់ពន្ធត្រូវបង់
- អភិបាល បណ្ណាធិការ កម្មសិទ្ធិករសហគ្រាស ឬភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបំពេញថ្ងៃខែ ចុះហត្ថលេខា ឈ្មោះ និងបោះត្រារបស់សហគ្រាសនៅផ្នែកខាងក្រោមខាងស្តាំនៃទំព័រទី១ នៃលិខិតប្រកាសពន្ធសរុបប្រចាំខែនេះ។ ចំពោះភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបំពេញលេខសម្គាល់ដែលមាននៅលើអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិពីអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស។

****

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លិខិតប្រកាសពន្ធសរុប-ទីស្នាក់ការកណ្តាល
TOTAL TAX RETURN HEADQUARTER (TTRH001)

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតប្រកាសពន្ធសរុបប្រចាំខែ (ទីស្នាក់ការកណ្តាល)
MONTHLY TAX RETURN (HEADQUARTER)

ប្រចាំខែ Month [M M] ឆ្នាំ Year [Y Y Y Y]

I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) [ ] [ ] [ ] [ ] - [ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ]

ឈ្មោះសហគ្រាស/ស្ថាប័នដទៃទៀត
Name of enterprise/Other Entities

សកម្មភាពអាជីវកម្មចម្បង
Main Business Activity

អាសយដ្ឋាន
Address

II. ប្រភេទពន្ធដែលត្រូវប្រកាស / TYPE OF TAXES TO BE DECLARED

ល.រ No.	បរិយាយ Description	ស្រង់មកពីទម្រង់លិខិតប្រកាសពន្ធ From tax return form	ចំនួនទំព័រ Number of pages	ឥណទានយោង Credit carried forward	ចំនួនប្រាក់ពន្ធត្រូវបង់ Tax amount to be paid
០១	ពន្ធលើប្រាក់បៀវត្ស Tax on Salary	ទម្រង់ ពបវ ០១ Form TOS 01 (ទីស្នាក់ការ) Headquarter			៛
០២	ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benefit				៛
០៣	ពន្ធកាត់ទុក Withholding Tax	ទម្រង់ ពកទ ០៣ Form WT 03 (ទីស្នាក់ការ) Headquarter			៛
០៤	អាករលើតម្លៃបន្ថែម Value Added Tax (VAT)	ទម្រង់ ពណ ០១ Form T7 01 (ទីស្នាក់ការ) Headquarter		ឥណទានយោងទៅមុខ៖ Credit carried forward ៛	៛
០៥	ប្រាក់រំដោះពន្ធលើប្រាក់ចំណូល Prepayment of Tax on Income				៛
០៦	អាករពិសេសលើទំនិញ និងសេវាមួយចំនួន Specific tax on Certain Merchandises and Services				៛
០៧	អាករលើការស្នាក់នៅ Accomodation Tax				៛
០៨	អាករសម្រាប់ចំណីសាធារណៈ Public Lighting Tax				៛
០៩	ពន្ធ-អាករដទៃទៀត Other Taxes				៛
	សរុប Total				៛

**សូមអានសេចក្តីណែនាំ នៃការបំពេញលិខិតប្រកាស
Please read the instructions for filling tax return

សម្គាល់ៈ Note :

- ការទទួលលិខិតប្រកាសមិនបញ្ជាក់ថា ការប្រកាសពន្ធត្រឹមត្រូវឡើយ
  Receiving Tax Return doesn't mean your Tax Return declaration is correct
- ករណីលោកលោកស្រីត្រូវការធ្វើបច្ចុប្បន្នភាពព័ត៌មាន សូមអញ្ជើញមកទំនាក់ទំនងនៅការិយាល័យចុះបញ្ជី ទី០៦ នៃសាលាជាតិពន្ធដារ
  In case, You need to update information Please contact Tax Registration Bureau at 6th floor of Tax school
- លោក / លោកស្រី ត្រូវដាក់លិខិតប្រកាសនេះព្រមទាំងបង់ប្រាក់ពន្ធអាករយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់
  This return and payment must be presented by the 20th day of the next month.
- លោក / លោកស្រី នឹងទទួលរងការផាកពិន័យ ទៅតាមច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើលោក / លោកស្រី
  You will be subject to penalties according to law on taxation if you.
  - មិនបានដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ ទោះបីជាគ្មានប្រាក់អាករត្រូវបង់ក៏ដោយ
    Fail to file tax return to the tax administration even it is a nil return.
  - មិនបង់ ឬបង់យឺតយ៉ាវ នូវប្រាក់អាករដែលបានប្រកាស
    Do not pay or pay the tax declared late.
  - ធ្វើការប្រកាសក្លែងក្លាយ ឬបន្ទំ
    Making a false declaration.

សេចក្តីណែនាំអំពីការបំពេញ

ទម្រង់លិខិតប្រកាសពន្ធសរុបប្រចាំខែ (ទីស្នាក់ការកណ្តាល)

(ទម្រង់ TTRH001)

- បំពេញខែ និងឆ្នាំដែលត្រូវដាក់លិខិតប្រកាស

I. ព័ត៌មានសហគ្រាស

- បំពេញលេខអត្តសញ្ញាណកម្មសារពើពន្ធ ឈ្មោះសហគ្រាស/ស្ថាប័នដទៃទៀត សកម្មភាពអាជីវកម្មចម្បង និងអាសយដ្ឋាន

II. ប្រភេទពន្ធដែលត្រូវប្រកាស

- បំពេញចំនួនប្រាក់ពន្ធត្រូវបង់តាមប្រភេទពន្ធនីមួយៗ ដោយដកស្រង់ចេញពីទម្រង់លិខិតប្រកាសពន្ធរបស់ទីស្នាក់ការកណ្តាលដែលបានបញ្ជាក់នៅក្នុងតារាងក្រោយប្រភេទពន្ធនីមួយៗ រួចបំពេញនៅក្នុងតារាង "ចំនួនប្រាក់ពន្ធត្រូវបង់"
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *ពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម* ត្រូវស្រង់ចេញពីទម្រង់ *<u>ពបវ ០១</u>* របស់ទីស្នាក់ការកណ្តាល
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *ពន្ធកាត់ទុក* ត្រូវស្រង់ចេញពីទម្រង់ *<u>ពកទ ០៣</u>* របស់ទីស្នាក់ការកណ្តាល
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *អាករលើតម្លៃបន្ថែម ឬស្នើសុំជាឥណទានយោងទៅមុខ* ត្រូវដកស្រង់ចេញពីទម្រង់ *<u>ពត ០១</u>* របស់ទីស្នាក់ការកណ្តាល។ ក្នុងករណី ទីស្នាក់ការកណ្តាលមានឥណទានអាករលើតម្លៃបន្ថែម ត្រូវបំពេញចំនួនទឹកប្រាក់នៅត្រង់ប្រអប់ "ឥណទានយោងទៅមុខ" ដោយស្រង់ចេញពីទម្រង់ *<u>ពបវ ០១</u>* របស់ទីស្នាក់ការកណ្តាល។ ក្នុងករណី ទីស្នាក់ការកណ្តាលមានប្រាក់ អតប ត្រូវបង់ ត្រូវបំពេញចំនួនប្រាក់ពន្ធត្រូវបង់នៅត្រង់ប្រអប់ "ចំនួនប្រាក់ពន្ធត្រូវបង់" សម្រាប់អាករលើតម្លៃបន្ថែម ដោយស្រង់ចេញពីទម្រង់ *<u>ពបវ ០១</u>* របស់ទីស្នាក់ការកណ្តាល
- ចំនួនប្រាក់ពន្ធត្រូវបង់សម្រាប់ *ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករលើការស្នាក់នៅ អាករសម្រាប់បំភ្លឺសាធារណៈ និងពន្ធ-អាករដទៃទៀត* ត្រូវស្រង់ចេញពីទម្រង់ *<u>ពត ០១</u>* របស់ទីស្នាក់ការកណ្តាល
- ចំនួនទំព័រ ត្រូវបូកសរុបចំនួនទំព័រនៃលិខិតប្រកាសពន្ធតាមទម្រង់នីមួយៗរបស់ទីស្នាក់ការកណ្តាល បន្ទាប់ពីបានបំពេញរួចរាល់ និងត្រូវបំពេញចំនួនសរុបនៃទំព័រ និងចំនួនប្រាក់ពន្ធត្រូវបង់។

****

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លេខ ត៧ ០១ (ស្នាក់ការកណ្តាល)
FORM T7 01 (Headquarters)

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតប្រកាស (ទីស្នាក់ការកណ្តាល)

អាករលើតម្លៃបន្ថែម/អាករលើតម្លៃបន្ថែម (បន្ទុករបស់រដ្ឋ) អាករលើការស្នាក់នៅ អាករសម្រាប់បំភ្លឺសាធារណៈ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករពិសេសលើទំនិញ និងសេវាមួយចំនួន និងពន្ធអាករដទៃទៀត

RETURN FOR VALUE ADDED TAX, VALUE ADDED TAX (STATE CHARGE), ACCOMMODATION TAX, PUBLIC LIGHTING TAX, PREPAYMENT OF TAX ON INCOME SPECIFIC TAX ON CERTAIN MARCHANDISES AND SERVICES AND OTHER TAXES (HEADQUARTERS)

ប្រចាំខែ Month M M ឆ្នាំ Year Y Y Y Y

I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐

II. សរុបពន្ធអាករ / TOTAL AMOUNT OF TAXES

លរ No.	ប្រភេទអាករ Type of tax		គណទានយោង ឬបង្វិលសង Creddit carried forward or refund		អាករត្រូវបង់ Tax payable
០១	អាករលើតម្លៃបន្ថែម Value Added Tax		គណទានយោងទៅមុខ៖ Credit carried forward	៛	
០២	អាករលើតម្លៃបន្ថែម (បន្ទុករដ្ឋ) Value Added Tax (State charge)	☐	គណទានយោងទៅមុខ៖ Credit carried forward	៛	
		☐	អតបបន្ទុករដ្ឋសរុប៖ VAT State charge	៛	
០៣	ប្រាក់រំដោះពន្ធលើប្រាក់ចំណូល Prepayment of tax on income	☐	គណទានយោងទៅមុខ៖ Credit carried forward	៛	៛
០៤	អាករសម្រាប់បំភ្លឺសាធារណៈ Public Lighting tax				៛
០៥	អាករពិសេសលើទំនិញ និងសេវាមួយចំនួន Specifi tax on certain marchandises and services				៛
០៦	អាករលើការស្នាក់នៅ Accomodation tax				៛
០៧	ពន្ធ-អាករដទៃទៀត Other tax				៛

III. ប្រតិបត្តិការសរុប / Total Transaction

ក. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល / PREPAYMENT OF TAX ON INCOME

ប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងខែ / Current month of Prepayment of tax on income	01	៛
គណទានយោងពីខែមុន / Credit last month	02	៛
ប្រសិនបើប្រអប់លេខ 01 ដកប្រអប់លេខ 02 > សូន្យ សម្រាប់៖ If box (01-02) > 0 for: ប្រាក់រំដោះពន្ធត្រូវបង់ PPI to be paid		៛
ប្រសិនបើប្រអប់លេខ 01 ដកប្រអប់លេខ 02 < សូន្យ សម្រាប់៖ If box (01-02) < 0 for: គណទានយោងទៅមុខ As a credit forward		៛

សេចក្តីណែនាំអំពីការបំពេញ
ទម្រង់លិខិតប្រកាស (ទីស្នាក់ការកណ្តាល)
អាករលើតម្លៃបន្ថែម អាករលើតម្លៃបន្ថែម (បន្ទុករបស់រដ្ឋ)
អាករលើការស្នាក់នៅ អាករសម្រាប់បំភ្លឺសាធារណៈ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល
អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងពន្ធអាករដទៃទៀត
(ទម្រង់ ពត 01 (ស្នាក់ការកណ្តាល) / T7 01 (Headquarter))

- បំពេញខែ និងឆ្នាំដែលត្រូវដាក់លិខិតប្រកាស

I. ព័ត៌មានសហគ្រាស

- បំពេញលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាស

II. សរុបពន្ធអាករ

- *អាករលើតម្លៃបន្ថែម* ត្រូវបំពេញនៅត្រង់ប្រអប់ "ឥណទានយោងទៅមុខ" ឬ"អាករត្រូវបង់" ដោយដកស្រង់លទ្ធផលពីការគណនាក្នុងទំព័រទី២ នៃទម្រង់លិខិតប្រកាសនេះ
- *អាករលើតម្លៃបន្ថែម (បន្ទុករដ្ឋ)* ត្រូវបំពេញនៅត្រង់ប្រអប់ "ឥណទានយោងទៅមុខ" ឬ "អតប បន្ទុករដ្ឋសរុប" ដោយដកស្រង់លទ្ធផលពីការគណនាក្នុងទំព័រទី២ នៃទម្រង់លិខិតប្រកាសនេះ
- *ប្រាក់រំដោះពន្ធលើប្រាក់ចំណូល* ត្រូវបំពេញនៅត្រង់ប្រអប់ "ឥណទានយោងទៅមុខ" ឬ"អាករត្រូវបង់" ដោយដកស្រង់លទ្ធផលពីការគណនាពីចំណុច III.ក ក្នុងទំព័រទី១
- *អាករសម្រាប់បំភ្លឺសាធារណៈ អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករលើការស្នាក់នៅ និងពន្ធ-អាករដទៃទៀត* ត្រូវបំពេញត្រង់ប្រអប់ "អាករត្រូវបង់" សម្រាប់ប្រភេទពន្ធនីមួយៗ ដោយដកស្រង់លទ្ធផលសរុបចេញពីពាក្យស្នើសុំបង់និងប្រកាសពន្ធតាមប្រព័ន្ធអនឡាញ ដែលត្រូវបានបង្ហាញស្វ័យប្រវត្តិតាមរយៈការប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) ទៅតាមប្រភេទពន្ធអាករនីមួយៗ។

III. ប្រតិបត្តិការសរុប

ក. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

- *ប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងខែ* ត្រូវដកស្រង់ចេញពីប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) រួចបំពេញនៅត្រង់ប្រអប់លេខ ១ និងបំពេញឥណទានយោងពីខែមុននៅត្រង់ប្រអប់លេខ ២។

ខ. អាករលើតម្លៃបន្ថែម

- ចំពោះការបំពេញ តារាងការទិញទំនិញនិងសេវាក្នុងខែ (Purchases record) និងតារាងការលក់ទំនិញនិងសេវាក្នុងខែ (Sales record) សម្រាប់អាករលើតម្លៃបន្ថែម ត្រូវដកស្រង់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing)។

គ. អាករលើតម្លៃបន្ថែម (បន្ទុករដ្ឋ)

- ចំពោះការបំពេញ តារាងការទិញទំនិញនិងសេវាក្នុងខែ (Purchases record) និងតារាងការលក់ទំនិញនិងសេវាក្នុងខែ (Sales record) សម្រាប់អាករលើតម្លៃបន្ថែម (បន្ទុករដ្ឋ) ត្រូវដកស្រង់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing)។

****

ខ. អាករលើតម្លៃបន្ថែម / VALUE ADDED TAX

ការទិញទំនិញ និងសេវាក្នុងខែ / Monthly Purchases and services

លេខ No.	ធាតុចូល Input			តម្លៃមិនរួមអតប Amount Exclusive of VAT		ទឹកប្រាក់អតប VAT Amount
០១	ការទិញជាប់អាករ-ក្នុងស្រុក ១០% Local Purchasse include VAT 10%	បុគ្គលជាប់អាករ taxable person	03		៛	04 ៛
០២	ការនាំចូលតាមអត្រា១០% Import 10%	អ្នកផ្គត់ផ្គង់ក្រៅប្រទេស Overseas suppliers	05		៛	06 ៛
០៣	ការទិញមិនជាប់អាករ Purchase Exclusive of VAT	បុគ្គលជាប់អាករ taxable person	07		៛	
		បុគ្គលមិនជាប់អាករ non-taxable person	08		៛	
០៤	ការទិញមិនអនុញ្ញាតឥណទាន Non creditable purchase	បុគ្គលជាប់អាករ taxable person	09		៛	
		បុគ្គលមិនជាប់អាករ non-taxable person	10		៛	
				សរុបទឹកប្រាក់អាករលើធាតុចូល (04+06) Total amount of input taxes		11 ៛

ការលក់ទំនិញ និងសេវាក្នុងខែ / Monthly Sales and Services

លេខ No.	ធាតុចេញ Output			តម្លៃមិនរួមអតប Amount Exclusive of VAT		ទឹកប្រាក់អតប VAT Amount
០១	ការលក់ជាប់អាករ ១០% Sales include VAT 10%	បុគ្គលជាប់អាករ taxable person	12		៛	13 ៛
		បុគ្គលមិនជាប់អាករ non-taxable person	14		៛	15 ៛
០២	ការនាំចេញ 0% Export 0%	អ្នកទិញក្រៅប្រទេស Overseas customer	16		៛	
០៣	ការលក់មិនជាប់អាករ Sales Exclude of VAT	បុគ្គលជាប់អាករ taxable person	17		៛	
		បុគ្គលមិនជាប់អាករ non-taxable person	18		៛	
				សរុបទឹកប្រាក់អាករលើធាតុចេញ (13+15) Total amount of output taxes		19 ៛

ប្រសិនបើប្រអប់លេខ 19 ដកប្រអប់លេខ 11 សូន្យ សម្រាប់ៈ If box (19-11) > 0 for:	អតបត្រូវបង់ Vat to be paid	៛
▶ ប្រសិនបើប្រអប់លេខ 19 ដកប្រអប់លេខ 11 < សូន្យ សម្រាប់ៈ If box (19-11) < 0 for:	▶ ឥណទានយោងទៅមុខ As a credit forward	៛

គ. អាករលើតម្លៃបន្ថែម (បន្ទុករដ្ឋ) / VALUE ADDED TAX (State charge)

ការទិញទំនិញ និងសេវាក្នុងខែ / Monthly Purchases of goods and services

លេខ No.	ធាតុចូល Input			តម្លៃមិនរួមអតប Amount Exclusive of VAT		ទឹកប្រាក់អតប VAT Amount
០១	ការទិញជាប់អាករ-ក្នុងស្រុក ១០% Local Purchasse include VAT 10%	បុគ្គលជាប់អាករ taxable person	20		៛	21 ៛
០២	ការនាំចូលតាមអត្រា១០% Import 10%	អ្នកផ្គត់ផ្គង់ក្រៅប្រទេស Overseas suppliers	22		៛	23 ៛
				សរុបទឹកប្រាក់អាករលើធាតុចូល (21+23) Total amount of input taxes		24 ៛

ការលក់ទំនិញ និងសេវាក្នុងខែ / Monthly Sale of goods and services

លេខ No.	ធាតុចេញ Output			តម្លៃមិនរួមអតប Amount Exclusive of VAT		ទឹកប្រាក់អតប VAT Amount
០១	ការលក់ជាប់អាករ ១០% Sales include VAT 10%	បុគ្គលជាប់អាករ taxable person	25		៛	26 ៛
		បុគ្គលមិនជាប់អាករ non-taxable person	27		៛	28 ៛
				សរុបទឹកប្រាក់អាករលើធាតុចេញ (26+28) Total amount of output taxes		29 ៛

ប្រសិនបើប្រអប់លេខ 29 ដកប្រអប់លេខ 24 > សូន្យ សម្រាប់ៈ If box (29-24) > 0 for:	អតបបន្ទុករដ្ឋ Vat state charge	៛
▶ ប្រសិនបើប្រអប់លេខ 29 ដកប្រអប់លេខ 24 < សូន្យ សម្រាប់ៈ If box (29-24) < 0 for:	▶ ឥណទានយោងទៅមុខ As a credit forward	៛

សម្គាល់ / Note:

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ យើងខ្ញុំមានសក្តិប៉ិត្រឫតាក់ច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយដែលមិនបានប្រកាសនោះទេ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ We have examined all items on this return and the annexes attached herewith. We have clear, correct, All supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ទម្រង់ ពបត ០១ (ស្នាក់ការកណ្តាល)
FORM TOS 01 (Headquarters)

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស (ទីស្នាក់ការកណ្តាល)
RETURN FOR TAX ON SALARY (HEADQUARTERS)

ប្រចាំខែ Month M M ឆ្នាំ Year Y Y Y Y

I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ Tax Identification Number (TIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐

II. សរុបប្រាក់ពន្ធ / TOTAL AMOUNT OF TAX

លរ No.	ប្រភេទពន្ធ Type of tax	ពន្ធត្រូវបង់ Tax payable
០១	ពន្ធលើប្រាក់បៀវត្ស Tax on Salary	រ
០២	ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benifit	រ

III. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសនជន / TAX ON SALARY FOR RESIDENT EMPLOYEES

លរ No.	ចំនួននិយោជិត No. of employees	ប្រាក់បៀវត្សត្រូវបើក Salary to be paid	សហព័ទ្ធ Spouse	ចំនួនកូនក្នុងបន្ទុក No. of minor children	អត្រាពន្ធ Tax rate	ពន្ធលើប្រាក់បៀវត្ស Tax on Salary
1		រ			0%	រ
2		រ			5%	រ
3		រ			10%	រ
4		រ			15%	រ
5		រ			20%	រ
សរុប Total		រ				រ

IV. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសនជន / TAX ON SALARY FOR NON-RESIDENT EMPLOYEES

លរ No.	ចំនួននិយោជិត No. of employees	ប្រាក់បៀវត្សត្រូវបើក Salary to be paid	អត្រាពន្ធ Tax rate	ពន្ធលើប្រាក់បៀវត្ស Tax on Salary
	A	B	C	D = B x C
1		រ	20%	រ

V. ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម / TAX ON SALARY ON FRINGE BENEFIT

លរ No.	ចំនួននិយោជិត No. of employees	ប្រាក់អត្ថប្រយោជន៍បន្ថែម Fringe benefit	អត្រាពន្ធ Tax rate	ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on salary on Fringe benefit
	A	B	C	D = B x C
1		រ	20%	រ

▶ តារាងលម្អិតអំពីពន្ធលើប្រាក់បៀវត្សចំពោះនិយោជិត និវាសនជន អនិវាសនជន និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
Details of tax on salary for resident, Non-resident employees and Tax on Salary on Fringe benefit

សម្គាល់ / Note:

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ យើងខ្ញុំមានសក្តិសមបំពេញតួនាទីជាក្រុមហ៊ុនច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវត្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយដែលមិនបានប្រកាសនោះទេ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ We have examined all items on this return and the annexes attached herewith. We have clear, correct, All supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

សេចក្តីណែនាំអំពីការបំពេញ

ទម្រង់លិខិតប្រកាសពន្ធលើប្រាក់ខែវិភក្ស (ទីស្នាក់ការកណ្តាល)

(ទម្រង់ ពបវ 09 (ស្នាក់ការកណ្តាល) / TOS 01 (Headquarter))

- បំពេញខែ និងឆ្នាំដែលត្រូវដាក់លិខិតប្រកាស

I. ព័ត៌មានសហគ្រាស

- បំពេញលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់សហគ្រាស

II. សរុបប្រាក់ពន្ធ

- បំពេញប្រាក់ពន្ធសរុបត្រូវបង់សម្រាប់ពន្ធលើប្រាក់ខែវិភក្សត្រូវបង់ ដោយសរុបប្រាក់ពន្ធលើប្រាក់ខែវិភក្សចំពោះនិយោជិតនិវាសនជនទៅតាមអត្រាពន្ធនិងស្ថានភាពអ្នកជាប់ពន្ធ (ចំណុចទី III) និងប្រាក់ពន្ធលើប្រាក់ខែវិភក្សចំពោះនិយោជិតអនិវាសនជន (ចំណុចទី IV)
- បំពេញប្រាក់ពន្ធសរុបត្រូវបង់សម្រាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមត្រូវបង់ ដោយដកស្រង់ចំនួនប្រាក់ពន្ធលើប្រាក់ខែវិភក្សចំពោះអត្ថប្រយោជន៍បន្ថែមតាមចំណុចទី V

III, IV, V. ពន្ធលើប្រាក់ខែវិភក្សចំពោះនិយោជិតនិវាសនជន អនិវាសនជន និងពន្ធលើប្រាក់ខែវិភក្សចំពោះអត្ថប្រយោជន៍បន្ថែម

